ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 24 / 05 / 2012
ម៉ោង (Time/Heure) : 11:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: UCH ARUN

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

# អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០១២

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន, ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង, មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** សេចក្តីណែនាំពាក់ព័ន្ធនឹងឯកសារដែលភាគីស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ សម្រាប់គោលបំណងនៃការសួរផ្ទញ់

កាលពីថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២ មានការពិភាក្សាលម្អិតមួយនៅក្នុងសវនាការ ទាក់ទិននឹងឯកសារដែលភាគីមានបំណងប្រើប្រាស់សម្រាប់គោលបំណងនៃការសួរផ្ទញ់។ ក្រុមមេធាវីការពារជនជាប់ចោទ នួន ជា បានអះអាងថា ឯកសារទាំងនេះពុំចាំបាច់ស្នើសុំឱ្យមានការទទួលយកនៅចំពោះមុខអង្គជំនុំជម្រះឡើយ (ប្រតិចារឹក, ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០១២, ទំព័រ ៨៣-៨៦)។

សម្ភារៈទាំងអស់ដែលភាគីមានបំណងស្នើសុំប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះ ដោយអនុលោមតាមក្របខ័ណ្ឌគតិយុត្តនៅ អ.វ.ត.ក និងដែលត្រូវបានបញ្ជាក់ដោយសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ទាក់ទិននឹងឯកសារ

E199

មកទល់នឹងពេលបច្ចុប្បន្ន (ឯកសារ E185 និងឯកសារ E190) ត្រូវបំពេញលក្ខខណ្ឌ ដូចមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ដោយមិនគិតអំពីគោលបំណងនៃការប្រើប្រាស់ឯកសារទាំងនោះឡើយ។

ឯកសារណាមួយដែលភាគីមានបំណងប្រើប្រាស់នៅចំពោះមុខអង្គជំនុំជម្រះ ហើយឯកសារនោះពុំទាន់ទទួលបានចំណាត់ថ្នាក់ជាឯកសារ E3 (ដែលត្រូវបានប្រើសម្រាប់ឯកសារនានាដែលត្រូវបានដាក់ ឬត្រូវបានចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ) ឬមិនត្រូវបានលើកឡើងនៅក្នុងបញ្ជីឯកសារណាមួយ ដែលត្រូវបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវបំពេញលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងការដាក់ឯកសារថ្មី។ អនុលោមតាមគោលការណ៍ស្តីពីការជំនុំជម្រះប្រកបដោយយុត្តិធម៌ដែលត្រូវបានទទួលស្គាល់ លក្ខខណ្ឌអប្បបរមាសម្រាប់ការសំអាងទៅលើឯកសារមួយនៅសវនាការ ដែលឯកសារនោះពុំស្ថិតនៅចំពោះមុខអង្គជំនុំជម្រះនៅឡើយ ឬត្រូវបានស្នើសុំឱ្យដាក់នៅចំពោះមុខអង្គជំនុំជម្រះ គឺជាបញ្ហាពាក់ព័ន្ធនឹងពេលវេលានៃការដាក់ឯកសារទៅក្នុងសំណុំរឿង និង/ឬ ស្នើសុំការទទួលយកឯកសារនេះ ដោយអនុលោមតាមអនុវិធាននេះ។

ការធានាថាឯកសារត្រូវបានដាក់ទាន់ពេលវេលា និងមានការជូនដំណឹងគ្រប់គ្រាន់ជាមុនមកអង្គជំនុំជម្រះ និងភាគីដទៃទៀតអំពីឯកសារទាំងអស់ដែលភាគីណាមួយលើកយកមកធ្វើជាសំអាងក្នុងការសួរដេញដោលសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី ឬអ្នកជំនាញ គឺជាបន្ទុករបស់ភាគីដែលស្នើសុំយកឯកសារនោះមកធ្វើជាសំអាង។